**Weekly Bulletin (Week4) May, 2010**

## ព្រឹត្តិបត្រ ព័ត៌មានប្រចាំសប្តាហ៍ កសិកម្ម និងអភិវឌ្ឍន៍ជនបទ

## ផលកៅស៊ូនឹងកើនឡើង៤ឆ្នាំខាងមុខ

*(អេវីរីដេ ៣១ ឧសភា ២០១០)*

អភិបាលខេត្តរតនគិរីបានអះអាងថានៅក្នុងអំឡុងពេលយ៉ាងយូរបួនឆ្នាំទៀត ដំណាំកៅស៊ូនៅក្នុងខេត្តនេះនឹងកើនឡើងខណៈពេលដែលនៅពេលនេះកំពុងតែទទួលបាន ចំណាប់អារម្មណ៍ពីក្រុមហ៊ុនវិនិយោគនានាលើដំណាំប្រភេទនេះ។ លោកប៉ាវហមផាន អភិបាលខេត្ត រតនគិរីបានអះអាង កាលពីចុងសប្តាហ៍កន្លង ទៅនេះថាក្រៅពីទិន្នផលកៅស៊ូដែលកសិករកំពុង ប្រមូលពីកៅស៊ូដែលដាំតាំង ពីឆ្នាំ១៩៦៥មក នោះខេត្តនេះសព្វថ្ងៃកំពុងតែប្រែក្លាយឱ្យទៅជាខេត្តនាំមុខគេមួយលើដំណាំកៅស៊ូ។ លោកអភិបាលខេត្តមិនបាន ផ្តល់នូវតួលេខអំពីទិន្នផល នៃដំណាំកៅស៊ូ កំពុងតែទទួល បានការចាប់អារម្មណ៍ពីក្រុមហ៊ុនវិនិយោគជាច្រើន។ លោកបានបញ្ជាក់ថា"ក្រៅពីដំណាំកៅស៊ូនៅលើផ្ទៃដី២៣០០ហិកតាដែល ដាំតាំងពីឆ្នាំ១៩៦៥មក ឆ្នាំនេះយើងបាន ពង្រីកការដាំបានប្រមាណជា ជាង១ម៉ឺនហិកតាទៀត" ។ លោកបានបញ្ជាក់ទៀតថា "ឥឡូវនេះវាកំពុងតែចាប់ផ្តើមទេតែ៤ទៅ៥ឆ្នាំទៀតទិន្នផលកៅស៊ូយើងនឹង ទទួលបានផលពេញទំហឹងហើយក៏រំពឹងថានឹងមានការកែច្នៃនៅនឹងខេត្តថែមទៀតផង"។

## អគ្គិសនីមានភ្លើងផ្គត់ផ្គត់តែ២៥០មេហ្គាវ៉ាត់

*(អេវីរីដេ ៣១ ឧសភា ២០១០)*

ភ្លើងអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងទីក្រុងភ្នំពេញបានខ្វះនៅពេលធាតុអាកាសក្តៅខ្លាំងជាហេតុតម្រូវ ឱ្យមានការកាត់ផ្តាច់ឆ្លាស់វេណគ្នានៅតំបន់ខ្លះ ហើយការខ្វះបែបនេះអាចនឹងកើតមានម្តង ទៀតនៅរដូវ ប្រាំងឆ្នាំ២០១១ ព្រោះពីពេលនេះទៅដល់រដូវប្រាំង ឆ្នាំ២០១១មិន មានប្រភពភ្លើងថ្មីណាមកបន្ថែមពីលើភ្លើងរបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជានេះទេ ។ តែប្រសិនបើវៀតណាមផ្តល់ភ្លើងឱ្យកម្ពុជាតាមកិច្ចព្រមព្រៀងគ្នាចំនួន២០០មេហ្គាវ៉ាត់នោះបញ្ហាខ្វះភ្លើងនៅ ភ្នំពេញទំនងមិនអាចកើតមានទេសម្រាប់រដូវប្រាំងឆ្នាំ ក្រោយនោះ។ប្រភពព័ត៌មាន ពីមន្ត្រីក្រុមហ៊ុនអគ្គិសនីកម្ពុជាមួយរូបបាននិយាយឱ្យដឹងនៅថ្ងៃទី២៨ឧសភាឆ្នាំ២០១០ថា តម្រូវការភ្លើង សម្រាប់ប្រើប្រាស់នៅទីក្រុងភ្នំពេញក្នុងរដូវ ក្តៅនេះពេលឡើងខ្ពស់ បំផុតគឺរហូតដល់ទៅប្រមាណពី២៨០-២៩០មេហ្គាវ៉ាត់ឯភ្លើងដែលក្រុមហ៊ុនអគ្គិសនី មានសម្រាប់ផ្គត់ផ្គង់តែប្រមាណពី ២៤០ទៅ២៥០មេហ្គាវ៉ាត់ប៉ុណ្ណោះ។ ដោយសារភ្លើងមានមិនគ្រប់គ្រាន់នេះហើយដែលនាំទៅដល់ការកាត់ផ្តាច់ឆ្លាស់វេណគ្នានៅពេល មានតម្រូវការខ្ពស់នោះ។ប្រភពដដែល បានឱ្យដឹងទៀតថា បន្ទាប់ពីមានភ្លៀង ធ្លាក់ខ្លះមកអាកាសធាតុបានចុះត្រជាក់បន្តិចការប្រើប្រាស់ភ្លើងក៏ថយចុះបន្តិចដែរ។

## ត្រីមាសទី១ ឆ្នាំ ២០១០ វិនិយោគទុននៅកម្ពុជាធ្លាក់ចុះ ៨%

*(ដើមអំពិល ៣១ ឧសភា ២០១០)*

ភ្នាក់ងារវិនិយោគទុនកម្ពុជា បានឱ្យដឹងថា វិនិយោគទុនកម្ពុជាក្នុងត្រីមាសទី១ ឆ្នាំ ២០១០បានធ្លាក់ចុះ ៨% គិតជាទឹកប្រាក់ស្មើនឹង ៨៤៦លានដុល្លារសហរដ្ឋអាមេរិក ដែលក្នុងរយៈពេលដូចគ្នានៅឆ្នាំ ២០០៩មានទឹកប្រាក់ ៩២២លានដុល្លារ ។

## បញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជាជាក្តីកង្វល់ថ្មី

*(កោះសន្តិភាព ២៨ ឧសភា ២០១០)*

ការប្រែប្រួលអាកាសធាតុកំពុងបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើផលិតកម្ម កសិកម្ម ធនធានទឹក សុខភាពមនុស្ស ព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី ។ គ្រោះទឹកជំនន់ ភាពរាំងស្ងួត ខ្យល់ព្យុះ និងគ្រោះមហន្តរាយធម្មជាតិផ្សេងទៀតបានកើតឡើងកាន់តែញឹកញាប់ និងខ្លាំងក្លា ព្រមទាំងផ្តល់នូវបញ្ហាជាច្រើននៅពេលបច្ចុប្បន្ន និងអនាគតដូចជា ដីខូចគុណភាព បាត់បង់ជីវៈចំរុះ ការរេចរិលព្រៃឈើ និងបាត់បង់ពូជដំណាំកសិកម្មក្នុងស្រុកជាដើម ។ ទាំងនេះបង្កមកពីឥទ្ធិពលអវិជ្ជមាននៃសារធាតុគីមីមួយផ្នែកក្នុងចំណោមឥទ្ធិពលដទៃទៀត ។ វិស័យកសិកម្មរួមចំណែកក្នុងការធ្វើឱ្យមានការប្រែប្រួលអាកាសធាតុផងដែរតាមរយៈការកាប់ព្រៃឈើ ការធ្វើកសិកម្មប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមី និងការប្រើប្រាស់ទឹកជាដើម ។

## មន្ត្រីជំនាញដុតកំទេចចោលសាច់ខូចគុណភាព និងទំនិញមានសារធាតុគីមី

*(កោះសន្តិភាព ២៨ ឧសភា ២០១០)*

សាច់ខូចគុណភាព និងទំនិញហួសកាលបរិច្ឆេទប្រើប្រាស់ និងទំនិញខ្លះមានលាយសារធាតុគីមីផងនោះត្រូវមន្ត្រីជំនាញកាំកុងត្រូលច្រកទ្វារប៉ោយប៉ែតយកទៅដុតកំទេចចោល ។ទំនិញទាំងនោះរួមមានសាច់មាន់ និងឆ្អឹងមាន់ខូចគុណភាពចំនួន ៤៥០គីឡូក្រាម និងទឹកក្រូចម៉ាកប៊ុបកូឡាចំនួន ១៨០ដប ផ្លែរំដេញត្រាំ ១០០គីឡូក្រាម និងទំពាំងត្រាំ ១៤០គីឡូក្រាម ។

## ពាណិជ្ជកម្មសៀមវាយលុកទីផ្សារកម្ពុជា

*(ដើមអំពិល ២៨ ឧសភា ២០១០)*

ពាណិជ្ជករសៀម ជាពិសេសផលិតផលកសិកម្ម គ្រឿងសំអាង និងគ្រឿងឧបភោគបរិភោគមួយចំនួនទៀត បានចាប់ផ្តើមវាយលុកទីផ្សារកម្ពុជាជាថ្មី ។ លោកឆះឡូថន ផៅវីបូន ភារៈធារីស្ថានទូតសៀមប្រចាំកម្ពុជា បានបញ្ជាក់ថា ចំណូលពីការនាំចូលផ្លែឈើ ក្នុងប្រទេសកម្ពុជាក្នុងមួយឆ្នាំៗបានប្រមាណ ១ពាន់លានបាត ។ លោកបញ្ជាក់បន្ថែមថា ពាណិជ្ជកម្មក្រៅប្រទេសរវាងសៀម និងកម្ពុជាកាលពីឆ្នាំ ២០០៩មានទឹកប្រាក់ចំនួន ១.៩៥៨ លានដុល្លារសហរដ្ឋអាមេរិក ។

## គាត ឈន់: ការវិនិយោគលើវិស័កសិកម្ម និងវិស័យសហគ្រាសខ្នាតតូច និងមធ្យម ជាគោលដៅសំខាន់

*(ដើមអំពិល ២៧ ឧសភា ២០១០)*

លោកឧបនាយករដ្ឋមន្ត្រីគាត ឈន់ បានប្រាប់ប្រតិភូវិនិយោគទុននៃប្រទេសជប៉ុនថា បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការចាប់អារម្មណ៍ជាសំខាន់ ទៅលើការវិនិយោគវិស័យកសិកម្ម និងវិស័យសហគ្រាសខ្នាតតូចនិងមធ្យមព្រោះថា ការនាំចេញអង្ករពីកម្ពុជាទៅបណ្តាប្រទេសអឺរ៉ុប គឺពុំមានការបង់ពន្ធឡើយ។ លោកមានប្រសាសន៍បន្តថា ការធ្វើអាជីវកម្មរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជាគឺជាការវិនិយោគល្អបំផុត ព្រោះបច្ចុប្បន្នយើងត្រូវការទុនយ៉ាងច្រើនដើម្បីកសាងរោងម៉ាស៊ីនកិនស្រូវមានលក្ខណៈស្តង់ដារអន្តរជាតិដើម្បីកិនស្រូវឱ្យក្លាយជាអង្ករសម្រាប់នាំចេញទៅសហគមន៍អឺរ៉ុប ហើយអ្នកវិនិយោគជប៉ុនក៏អាចប្រើប្រាស់វត្ថុធាតុដើមពីស្រូវផលិតជាស្រាសាកេផងដែរ។

## ម៉ាឡេស៊ីនឹងជួយបណ្តុះធនធានមនុស្ស

*(អេវីរីដេ ២៧ ឧសភា ២០១០)*

ឯកអគ្គរដ្ឋទូតថ្មីរបស់ម៉ាឡេស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបានសន្យាថានឹងជួយជំរុញឱ្យរដ្ឋាភិបាលម៉ាឡេស៊ីជួយកម្ពុជាលើវិស័យ បណ្តុះបណ្តាលធនធានមនុស្សតាមរយៈការផ្តល់ អាហាររូបការណ៍ដល់និស្សិតកម្ពុជាព្រមទាំងខិតខំទាក់ទាញវិនិយោគិនម៉ាឡេស៊ីឱ្យមកបណ្តាក់ទុននៅកម្ពុជា។ជាពិសេសជំរុញឱ្យអ្នកវិនិយោគម៉ាឡេស៊ីសាងសង់រោងម៉ាស៊ីនកិនស្រូវដ៏ធំមួយនៅកម្ពុជាដើម្បីនាំអង្ករចេញទៅម៉ាឡេស៊ីដោយសារអង្ករខ្មែរ មានគុណភាពល្អ ។

## សង្គមស៊ីវិលប្រារព្ធពិធីរំឭកដល់ការស្លាប់ដោយសារជំងឺអេដស៍

*(វិទ្យុអាស៊ីសេរី ២៦ ឧសភា ២០១០)*

របាយការណ៍ឆ្នាំ ២០០៦ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគធ្លាប់បានបង្ហាញថា ប្រទេសកម្ពុជាមានអ្នកផ្ទុកមេរោគចំនួន ៦៧.២០០នាក់ ក្នុងនោះមានប្រមាណជាង ៥ម៉ឺននាក់ដែលត្រូវការព្យាបាលជំងឺឱកាសនិយម និងថ្នាំព្យារជីវិត។ ក្នុងនោះដែរ អ្នកជំងឺប្រមាណ ៣ម៉ឺននាក់ទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងជំងឺឱកាសនិយមពីក្រសួងសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ ប្រទេសកម្ពុជាតាមរយៈជំនួយសហប្រតិបត្តិការបានចំណាយប្រាក់ក្នុងការផ្តល់ជំងឺឱកាសនិយម សេវាដឹកជញ្ជូន ការឧបត្ថម្ភអាហារ និងថ្នាំប្រឆាំងមេរោគអេដស៍ដល់អ្នកជំងឺអេដស៍ប្រមាណ ៥០លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ។

## ជប៉ុនចាប់អារម្មណ៍ស្ករត្នោតខ្មែរធ្វើស្ករគ្រាប់

*(អេវីរីដេ ២៦ ឧសភា ២០១០)*

ក្រុមហ៊ុន SUZUKI Chemical Company Ltd របស់ប្រទេសជប៉ុនកំពុងផលិតស្ករគ្រាប់ធ្វើពីស្ករត្នោតខ្មែរ ដើម្បីដាក់លក់សាកល្បងនៅទីផ្សារប្រទេសជប៉ុន។នេះជាសញ្ញាប្រសើរមួយសម្រាប់ ប្រជាកសិករខ្មែរ ដែលប្រកបរបរផលិតស្ករត្នោត។ **លោកឡាង សេងហ៊ង**ប្រធានសហគ្រាសនៃមជ្ឈ មណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) បានប្រាប់ភ្នំពេញ ប៉ុស្តិ៍កាលពីថ្ងៃអង្គារថាក្រុមហ៊ុនSUZUKI Chemical Company Ltd ដែលមានមូលដ្ឋាននៅក្នុងទីក្រុងណាហ្គោយ៉ាប្រទេសជប៉ុនកំពុងធ្វើការផលិតស្ករគ្រាប់ធ្វើពីស្ករត្នោតខ្មែរដើម្បីដាក់លក់សាកល្បងនៅ ក្នុងប្រទេសជប៉ុន។ លោក បានបញ្ជាក់ថា " យើងសង្ឃឹមថាការលក់សាកល្បងនេះនឹង ទទួលបានជោគជ័យហើយ ក្រុមហ៊ុនអាចឈានទៅដល់ការ បើករោងចក្រមួយព្រោះថាស្ករត្នោតខ្មែរមានគុណភាព និងឱជារសពិសេស"។សហគ្រាសសេដាកបានឱ្យដឹងថាកាលពីខែមេសាក្រុមហ៊ុន SUZUKI Chemical Company Ltdបាននាំយកស្ករត្នោតខ្មែរ២តោនក្នុង តម្លៃ ប្រមាណ៣000 ដុល្លារអាមេរិក ទៅប្រទេសជប៉ុន ដើម្បីផលិតស្ករគ្រាប់លក់សាកល្បងនៅទីនោះ។

## អត្រាមរណភាពកុមារនៅប្រទេសកម្ពុជា

*(វិទ្យុអូស្ត្រាលី ២៥ ឧសភា ២០១០)*

ការសិក្សាថ្មីមួយបានរកឃើញថា ប្រទេសកម្ពុជាមានការរីកចំរើនយ៉ាងខ្លាំងនៅក្នុងការកាត់បន្ថយមរណភាពកុមារអាយុតិចជាង ៥ឆ្នាំ និងថាប្រទេសកម្ពុជាបានបំពេញរួចហើយនូវគោលបំណងអភិវឌ្ឍន៍សហស្សវត្សរ៍ជាតិចំពោះអត្រាមរណភាពកុមារ។ ការសិក្សារកឃើញថា កុមារ១២នាក់បានស្លាប់ក្នុងកុមារ ១ពាន់នាក់ដែលមានអាយុចន្លោះពី ១ឆ្នាំទៅ ៥ឆ្នាំ។ ហើយអត្រាមរណភាព ២៤.៥ក្នុងចំណោះកុមារ ១ពាន់នាក់ដែលមានអាយុតិចជាង ១ឆ្នាំ។ យោងតាមទិន្នន័យនេះ ប្រទេសកម្ពុជាមានអត្រាមរណភាពកុមារខ្ពស់បំផុតទី៤ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយគ្រាន់បើជាងប្រទេសភូមាបន្តិច។ ប្រទេសឡាវមានចំនួនមរណភាពកុមារច្រើនបំផុតនៅក្នុងតំបន់ ចំណែកឯប្រទេសម៉ាឡេស៊ីមានចំនួនទាបជាងគេបង្អស់។

## ព្រៃនាម ២០០ហិកតាវងការដុតបំផ្លាញនៅខេត្តពោធិសាត់

*(វិទ្យុអាស៊ីសេរី ២៥ ឧសភា ២០១០)*

ព្រៃនាមដែលជាប្រភេទព្រៃលិចទឹកប្រមាណ ២០០ហិកតានៅក្នុងភូមិរាំងទិល ឃុំរាំងទិល ស្រុកកណ្ដៀង ខេត្តពោធិសាត់បានរងការដុតបំផ្លាញពីជនមិនស្គាល់មុខ ដែលគេសង្ស័យថាជាក្រុមបទល្មើសនេសាទ។ បើតាមមន្ទីរបរិស្ថានខេត្តពោធិសាត់ឱ្យដឹងថាក្នុងខេត្តនេះមានព្រៃលិចទឹកប្រមាណ ៥០.៣៨៥ហិកតា ស្ថិតនៅក្នុងភូមិចំនួន ១៥ នៃស្រុកចំនួន ៣គឺស្រុកកណ្ដៀង ស្រុកបាកាន និងស្រុកក្រគរ។

## ក្រសួងសុខាភិបាលអំពាវនាវប្រជាពលរដ្ឋធ្វើអនាម័យលំនៅដ្ឋាន

*(ដើមអំពិល ២៩ ឧសភា ២០១០)*

ក្រសួងសុខាភិបាលធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូបធ្វើការសំអាតលំនៅដ្ឋានកុំឱ្យមានជម្រកមូសខ្លានៅក្នុងផ្ទះ ដែលជាភ្នាក់ងារចម្លងជំងឺគ្រុនឈាម។ លោករដ្ឋមន្ត្រីម៉ម ប៊ុនហេងបញ្ជាក់ថា នៅឆ្នាំ ២០០៩កន្លងទៅ ជំងឺគ្រុនឈាមមានចំនួន ១១.៦៩៩ ករណី និងស្លាប់ ៣៨ករណី។ ចំនួននេះបានថយចុះប្រមាណ ២ដងបើធៀបនឹងឆ្នាំ ២០០៩កន្លងមក។

## រដ្ឋាភិបាលផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុន ៩៥ម៉ឺនហិកតា

*(រស្មីកម្ពុជា ២ មេសា ២០១០)*

លោកទេសរដ្ឋមន្ត្រីអ៊ឹម ឈុនលឹមរដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្មនិងសំណង់បានប្រកាសថា សម្បទានដីសេដ្ឋកិច្ចនៅទូទាំងប្រទេសដែលកំពុងមានសុពលកម្មមានចំនួន ៨៥ ក្រុមហ៊ុន សរុបផ្ទៃដីប្រហែលជា ៩៥ម៉ឺនហិកតា។ ប៉ុន្តែសមាគមសិទ្ធិមនុស្សអាដហុកបានបង្ហាញថា រដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចជូនក្រុមហ៊ុនឯកជនសរុបចំនួន ១.២០៨.១៨៥ ហិកតា រាប់មកដល់ឆ្នាំ ២០០៩។